# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០២២ គ.ជ.ប.ស.ជ.ណ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រឡងជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ឱ្យបម្រើការងារនៅ លេខាធិការដ្ឋានគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកណ្តាល

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកណ្តាល ត្រូវការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ចំនួន ៣៧រូប ដើម្បីបម្រើការងារនៅលេខាធិការដ្ឋាននៃគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកណ្តាល សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ដែលមានមុខតំណែងដូចខាងក្រោម ៖

**១- ផ្នែករដ្ឋបាល**

| | |
|---|---|
| - ការីកុំព្យូទ័រ | ចំនួន ១ រូប |
| - អ្នកយាម | ចំនួន ៦ រូប |
| - អ្នកបើកបររថយន្ត | ចំនួន ១ រូប |

**២- ផ្នែកប្រតិបត្តិការ**

| | |
|---|---|
| - អនុប្រធានផ្នែកប្រតិបត្តិការទទួលបន្ទុកភស្តុភារ | ចំនួន ១ រូប |
| - មន្ត្រីប្រតិបត្តិការ និងភស្តុភារ | ចំនួន ៣ រូប |
| - ការីវិទ្យុទាក់ទង | ចំនួន ២ រូប |

**៣- ផ្នែកហិរញ្ញវត្ថុ**

| | |
|---|---|
| - គណនេយ្យករ | ចំនួន ១ រូប |
| - បេឡាធិការ | ចំនួន ១ រូប |
| - ជំនួយការគណនេយ្យ | ចំនួន ១ រូប |

**៤- ផ្នែកបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ**

| | |
|---|---|
| - ជំនួយការបណ្តុះបណ្តាលអប់រំអ្នកបោះឆ្នោត និងព័ត៌មានសាធារណៈ(គ្រូបង្ហាត់) | ចំនួន ១៨ រូប |

**៥- ផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម**

- មន្ត្រីទទួល និងដោះស្រាយបណ្តឹង ចំនួន ២ រូប

I- **លក្ខខណ្ឌទូទៅនៃបេក្ខជន ÷**

- មានសញ្ជាតិខ្មែរ និងមានអាយុតាមការកំណត់ក្នុងលក្ខខណ្ឌដោយឡែក
- មានកិរិយាមារយាទល្អ និងសុចរិតទៀងត្រង់ គោរពច្បាប់ និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងក្រមសីលធម៌មន្ត្រីបោះឆ្នោត
- មានសិទ្ធិបោះឆ្នោតក្នុងខេត្ត
- មានសុខភាពល្អ
- មិនមែនជាមន្ត្រីតុលាការក្នុងក្របខ័ណ្ឌការងារ
- មិនមែនជាព្រះសង្ឆ ឬបព្វជិតសាសនា
- មិនមែនជាអភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោត សម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ
- មិនមែនជាមេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិ
- មិនមែនជាជនដែលតុលាការផ្តន្ទាទោស ដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ
- បេក្ខជនអាចដាក់ពាក្យបានតែមួយមុខតំណែងគត់
- បេក្ខនារី ឬ បេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិចនៅតំបន់ដែលមានជនជាតិដើមភាគតិចតាមចំនួនសមស្រប និងចំពោះបេក្ខជន និងបេក្ខនារីជាជនមានពិការភាព ដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងមុខតំណែង ត្រូវបានលើកទឹកចិត្ត ។

II - **លក្ខខណ្ឌបច្ចេកទេសដែលទាមទារដើម្បីបំពេញការងារជាក់លាក់មួយចំនួនដូចជា ÷**

- ត្រូវចេះអាន និងសរសេរអក្សរខ្មែរច្បាស់លាស់
- មានចំណេះដឹងទាក់ទងជាមួយមុខតំណែង
- សម្រាប់តួនាទីមួយចំនួន ទាមទារឱ្យមានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- មានលទ្ធភាពធ្វើដំណើរក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងរាជធានី ខេត្ត ឬក្នុងឃុំ សង្កាត់ ។

III- **លក្ខខណ្ឌដោយឡែក ៖**

១- ការីកុំព្យូទ័រ បេក្ខជនត្រូវមានអាយុយ៉ាងតិច ១៩ឆ្នាំ មានចំណេះដឹង និងចេះប្រើប្រាស់កុំព្យូទ័រច្បាស់លាស់ (ឆ្លងកាត់ការធ្វើតេស្តសមត្ថភាព)

* ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.000.000 រៀល ។

២- អ្នកយាម បេក្ខជនត្រូវមានអាយុយ៉ាងតិច ២០ឆ្នាំ មានបទពិសោធន៍ខាងការងារយាមល្បាត អគារឃ្លាំង ចេះអាន ចេះសរសេរភាសាខ្មែរ និងមានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន

* ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.000.000 រៀល ។

៣- អ្នកបើកបររថយន្ត បេក្ខជនត្រូវមានអាយុយ៉ាងតិច ២២ឆ្នាំ ចេះអាន និងសរសេរអក្សរខ្មែរច្បាស់លាស់ និងមានប័ណ្ណបើកបររថយន្ត បទពិសោធន៍ក្នុងការងារបើកបរ និងមានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន

* ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.000.000 រៀល ។

៤- គណនេយ្យករ បេក្ខជនត្រូវមានអាយុយ៉ាងតិច ២៥ឆ្នាំ និងមានសញ្ញាបត្របរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ខាងការងារគណនេយ្យ និងហិរញ្ញវត្ថុ ចាប់ពី៣ឆ្នាំ ឬបទពិសោធន៍

ការងារបោះឆ្នោតទាក់ទងគណនេយ្យ និងហិរញ្ញវត្ថុ ៣ដង ឡើងទៅ ព្រមទាំងមានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន

* ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល ។

៥- បេឡាធិការ បេក្ខជនត្រូវមានអាយុយ៉ាងតិច ២៥ឆ្នាំ និងមានសញ្ញាបត្របរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬមានបទពិសោធន៍ខាងការងារបេឡា ចាប់ពី ៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងបេឡា ៣ដង ឡើងទៅ ព្រមទាំងមានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន

* ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល ។

៦- ជំនួយការគណនេយ្យ បេក្ខជនត្រូវមានអាយុយ៉ាងតិច ២៥ឆ្នាំ និងមានសញ្ញាបត្របរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ខាងការងារគណនេយ្យ និងហិរញ្ញវត្ថុ ចាប់ពី៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងគណនេយ្យ និងហិរញ្ញវត្ថុ ៣ដង ឡើងទៅ ព្រមទាំងមានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន

* ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល ។

៧- អនុប្រធានផ្នែកប្រតិបត្តិការទទួលបន្ទុកភស្តុភារ បេក្ខជនត្រូវមានអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ញាបត្របរិញ្ញាបត្ររង ពាក់ព័ន្ធនឹងការងារចាត់ចែងគ្រប់គ្រងការងារស្តុក ឬមានបទពិសោធន៍ការងារគ្រប់គ្រងឃ្លាំងសម្ភារ និងការបែងចែកសម្ភារ ៣ឆ្នាំ ឬមានបទពិសោធន៍ខាងការងារបោះឆ្នោតផ្នែកភស្តុភារ ៣ដងឡើងទៅ

* ប្រាក់កម្រៃក្នុងមួយខែទទួលបាន ២.៥៦០.០០០ រៀល ។

៨- មន្ត្រីប្រតិបត្តិការ និងភស្តុភារ បេក្ខជនត្រូវមានអាយុយ៉ាងតិច ២៥ឆ្នាំ សញ្ញាបត្របរិញ្ញាបត្ររងពាក់ព័ន្ធនឹងការងារប្រតិបត្តិការ និងភស្តុភារ ឬមានបទពិសោធន៍ការងារប្រតិបត្តិការ និងភស្តុភារ ចាប់ពី ៣ឆ្នាំ ឬមានបទពិសោធន៍ខាងការងារបោះឆ្នោតផ្នែកប្រតិបត្តិការ និងភស្តុភារ ៣ដង

* ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល ។

៩- ការីវិទ្យុទាក់ទង បេក្ខជនត្រូវមានអាយុយ៉ាងតិច ២០ឆ្នាំ មានបទពិសោធន៍ខាងការងារវិទ្យុទាក់ទង ព្រមទាំងមានបទពិសោធន៍ខាងការងារទំនាក់ទំនងព័ត៌មានច្បាស់លាស់ និងមានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន

* ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.០០០.០០០ រៀល ។

១០- ជំនួយការបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ (គ្រូបង្ហាត់ទទួលបន្ទុកតាមក្រុង ស្រុក) បេក្ខជនត្រូវមានអាយុយ៉ាងតិច២៥ឆ្នាំ មានសញ្ញាបត្រចាប់ពីគ្រូបឋមសិក្សាឡើងទៅ ឬមានបទពិសោធន៍ការងារពាក់ព័ន្ធការងារបណ្តុះបណ្តាល ចាប់ពី៣ឆ្នាំ ឬមានបទពិសោធន៍ការងារបោះឆ្នោតពាក់ព័ន្ធការងារបណ្តុះបណ្តាល ៣ដង

* ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល ។

១១- មន្ត្រីទទួល និងដោះស្រាយបណ្តឹង បេក្ខជនត្រូវមានអាយុយ៉ាងតិច២៥ឆ្នាំ មានសញ្ញាបត្របរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ខាងការងារច្បាប់ចាប់ពី ៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងវិស័យច្បាប់ ៣ដង

* ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល ។

IV- **រយៈពេលបម្រើការងារ**

ចាប់ផ្តើមចូលបម្រើការងារពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៨ ។

V- **ទំនាក់ទំនងព័ត៌មាន**

អ្នកដែលមានបំណងដាក់ពាក្យជាបេក្ខជនតាមមុខតំណែងខាងលើនេះ សូមអញ្ជើញមកទាក់ទងដាក់ពាក្យសុំប្រឡងចូលបម្រើការងារនៅរៀងរាល់ម៉ោងធ្វើការនៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកណ្តាល ។

ពាក្យសុំចូលបម្រើការងារ នឹងមានចែកជូនដោយឥតគិតថ្លៃ ។

VI- **កាលបរិច្ឆេទនៃការទទួលពាក្យ ការកំណត់មុខតំណែងដែលត្រូវប្រឡងសរសេរ-QCM សម្ភាសន៍ និងធ្វើតេស្តកុំព្យូទ័រ**

- ការចាប់ផ្តើមទទួលពាក្យ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ ( វេលាម៉ោង ៧:00 ព្រឹក )
- ការឈប់ទទួលពាក្យ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៨ ( វេលាម៉ោង ១៧:៣0 នាទីល្ងាច )
- ការកំណត់មុខតំណែងដែលត្រូវប្រឡងសរសេរ-QCM សម្ភាសន៍ និងធ្វើតេស្តកុំព្យូទ័រ ៖
  + គណនេយ្យករ
  + បេឡាធិការ
  + ជំនួយការគណនេយ្យ
  + មន្ត្រីទទួល និងដោះស្រាយបណ្តឹង
- ការកំណត់មុខតំណែងដែលត្រូវប្រឡងសរសេរ-QCM និងធ្វើតេស្តកុំព្យូទ័រ ៖
  + ការីកុំព្យូទ័រ
- ការកំណត់មុខតំណែងដែលត្រូវប្រឡងសរសេរ-QCM និងសម្ភាសន៍ ៖
  + អនុប្រធានផ្នែកប្រតិបត្តិការទទួលបន្ទុកភស្តុភារ
  + មន្ត្រីប្រតិបត្តិការ និងភស្តុភារ
  + ជំនួយការបណ្តុះបណ្តាល អប់រំអ្នកបោះឆ្នោត និងព័ត៌មានសាធារណៈ
- ការកំណត់មុខតំណែងដែលត្រូវធ្វើសម្ភាសន៍ ៖
  + អ្នកយាម
  + អ្នកបើកបររថយន្ត
  + ការីវិទ្យុទាក់ទង
- ការបិទផ្សាយបញ្ជីឈ្មោះបេក្ខជនដែលត្រូវប្រឡងសរសេរ-QCM សម្ភាសន៍ និងធ្វើតេស្តកុំព្យូទ័រ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨
- ការប្រឡងសរសេរ-QCM សម្ភាសន៍ និងធ្វើតេស្តកុំព្យូទ័រ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨

VII- **ការអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

គណៈកម្មការរៀបចំការប្រឡង ត្រូវពិនិត្យសំណុំលិខិតរបស់បេក្ខជនដោយត្រូវធ្វើការពិនិត្យ និងជ្រើសរើសយកបេក្ខជនណាដែលមានលក្ខខណ្ឌល្អជាងគេ មកប្រឡងសរសេរ-QCM សម្ភាសន៍ និងធ្វើតេស្តកុំព្យូទ័រ ។

សំណុំលិខិតរបស់បេក្ខជនមិនត្រូវបានប្រគល់ជូនវិញទេ ។

VIII- **លទ្ធផលនៃការប្រឡងសរសេរ-QCM សម្ភាសន៍ និងធ្វើតេស្តកុំព្យូទ័រ**

លទ្ធផលនៃការប្រឡងសរសេរ-QCM សម្ភាសន៍ និងធ្វើតេស្តកុំព្យូទ័រ នឹងបិទផ្សាយ នៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកណ្តាល ។

**<u>បញ្ជាក់បន្ថែម</u>** :

- សញ្ញាបត្រ ឬ/និងលិខិតបញ្ជាក់ពីបទពិសោធន៍ការងារត្រូវធ្វើនីតានុកូលកម្ម ឬមានការបញ្ជាក់ពីសាមីស្ថាប័ន
- គ្រប់បេក្ខជនត្រូវមានអ្នកធានាដឹងឮ យ៉ាងតិចមួយនាក់
- បេក្ខជនទាំងអស់ត្រូវធានាថា ក្រោយពីពេលដែលត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារក្នុងមុខតំណែងណាមួយនោះត្រូវសុខចិត្តទទួលយកប្រាក់កម្រៃដូចបានកំណត់ដែលនឹងត្រូវបើកជូនក្រោយ ពី គ.ជ.ប បានទទួលប្រាក់ពីរតនាគារជាតិ
- មាត្រា២៤ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចែងថា ... មន្ត្រីរាជការ ដែលត្រូវបានជ្រើសរើសជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារឱ្យ គ.ជ.ប ត្រូវរក្សាបៀវត្ស អតីតភ្ជាពការងារសម្រាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍ នៅអង្គភាពដើមរបស់ខ្លួនដដែល ។

ថ្ងៃព្រហស្បតិ៍ ៤រោជ ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៨

**ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(។)**

**ប្រធាន**

**ស៊ិក ប៊ុនហុក**